# គន្លឹះសំខាន់ក្នុងការជ្រើសរើសការដាំដុះដំណាំធ្វើជាម្ហូបអាហារ

ឥឡូវនេះថាតើអ្នកបានសម្រេចចិត្តបង្កើតសួនច្បាររបស់អ្នកនៅត្រង់ណា អ្នកអាចសម្រេចចិត្តថាតើដំណាំឈើហូបផ្លែ ដំណាំបន្លែ ឬរុក្ខជាតិក្លិនក្រអូបប្រើជាគ្រឿងដាំស្លណាខ្លះដែលអ្នកចង់ដាំដុះ។

- ការដាំដុះដំណាំឈើហូបផ្លែ ដំណាំបន្លែ ឬរុក្ខជាតិក្លិនក្រអូបប្រើជាគ្រឿងដាំស្លដែលអ្នកចូលចិត្តបរិភោគ ឬដាំស្លអាចធ្វើឱ្យអ្នកមានការជំរុញទឹកចិត្តបន្តការថែទាំសួនច្បារ។ នេះក៏អាចជួយសន្សំសំចៃប្រាក់អ្នកពីការចំណាយនៅទីផ្សារទំនើបផងដែរ។

- តើមានរុក្ខជាតិដែលអ្នកចូលចិត្ត រូបរាង ឬហិតក្លិនទេ? សូមពិចារណាដាំដុះដំណាំទាំងនេះផងដែរ!

- ដាំគ្រាប់ពូជ ឬកូនបណ្ដុះរបស់អ្នកនៅចំពេលត្រឹមត្រូវនៃឆ្នាំ។ ប្រសិនបើអ្នកនឹងទិញគ្រាប់ពូជ ឬកូនបណ្ដុះពីកន្លែងបណ្ដុះ និងលក់កូនរុក្ខជាតិ ព័ត៌មានអំពីការដាំដុះនេះច្រើនតែមានដាក់នៅលើស្លាក ឬបុគ្គលិកអាចជួយអ្នកបាន។

  ប្រសិនបើអ្នកបានទទួលគ្រាប់ពូជ ឬកូនបណ្ដុះពីអ្នកថែទាំសួនច្បារម្នាក់ទៀត សុំស្នើយោបល់ពីពួកគេ។

- រុក្ខជាតិផ្សេងៗគ្នា ត្រូវការពន្លឺថ្ងៃក្នុងបរិមាណខុសៗគ្នា។ បរិមាណពន្លឺថ្ងៃដែលសួនច្បាររបស់អ្នកទទួលបាននឹងមានផលប៉ះពាល់ដល់រុក្ខជាតិដែលអ្នកអាចដាំដុះ។

- តើមានដំណាំធ្វើជាម្ហូបអាហារណាមួយដែលពិបាករក ឬពិបាកទិញនៅហាងទេ? ឬតើមានអ្វីមួយដែលអ្នកបរិភោគច្រើនទេ? ដំណាំធ្វើជាម្ហូបអាហារទាំងនេះគឺល្អដើម្បីសាកល្បងដាំដុះនៅផ្ទះ។

- រុក្ខជាតិខ្លះត្រូវការកន្លែងធំ ហើយខ្លះទៀតត្រូវការកន្លែងតូច។ នៅពេលរៀបចំផែនការសួនច្បាររបស់អ្នកសូមពិចារណាពីកម្ពស់ ឬទទឹងរបស់រុក្ខជាតិដែលនឹងដុះលូតលាស់។

- ប្រសិនបើអ្នកចង់បានគំនិតនានា អំពីដំណាំធ្វើជាម្ហូបអាហារដែលដុះលូតលាស់ល្អនៅក្នុងតំបន់របស់អ្នក អ្នកអាចសាកល្បងសួរអ្នកជិតខាង ទៅមើលសួនសហគមន៍ សួរនរណាម្នាក់នៅកន្លែងបណ្ដុះ និងលក់កូនរុក្ខជាតិ ឬរកមើលតាមអនឡាញ។

**សម្រាប់ធនធានបន្ថែម សូមចូលមើលគេហទំព័រ៖**
**www.foodfromhome.org/resources/**

